ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# ឯកសារស្រាវជ្រាវគំរូបច្ចេកទេស
# ចិញ្ចឹមមាន់ស្រុក
# Native Chicken Raising




រៀបចំដោយ

**គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**
**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (អេ.អ.ឌី.ប៊ី)**



ខែមិថុនា ឆ្នាំ២០២៣

## អារម្ភកថា

ការចិញ្ចឹមមាន់ពូជក្នុងស្រុកជាលក្ខណៈគ្រួសារមានសារសំខាន់ណាស់សម្រាប់ប្រជាកសិករក្នុងការលើកកម្ពស់ជីវភាពរស់នៅ តាមរយៈការបង្កើនអាហារូបត្ថម្ភ និងផ្តល់ប្រាក់ចំណូលដល់គ្រួសារ។ ឯកសារណែនាំអំពីបច្ចេកទេសចិញ្ចឹមមាន់ជាច្រើនត្រូវបានសិក្សារៀបចំ និងចងក្រងដោយស្ថាប័នរដ្ឋ ផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងបានធ្វើការផ្សព្វផ្សាយបណ្តុះបណ្តាលដល់ប្រជាកសិករដើម្បីបង្កើនផលិតភាព។ ទោះជាយ៉ាងនេះក្តី តាមរយៈនៃការចុះសិក្សាផ្ទាល់ដល់មូលដ្ឋានផលិតកម្មឃើញថាប្រជាកសិករមួយចំនួនបាននិងកំពុងជួបប្រទះនូវបញ្ហាជាច្រើនក្នុងការចិញ្ចឹមមាន់ឱ្យទទួលបានជោគជ័យ ដោយសារការរាតត្បាតនៃជំងឺឆ្លងរាលដាលផ្សេងៗ និងការថែទាំមិនបានដិតដល់ ដែលបណ្តាលមកពីកង្វះខាតនូវបច្ចេកទេសសមស្រប និងបទពិសោធន៍ល្អៗក្នុងការចិញ្ចឹមមាន់របស់ប្រជាកសិករ។

ដើម្បីរួមចំណែកអភិវឌ្ឍន៍ការចិញ្ចឹមមាន់នៅកម្ពុជា ក៏ដូចជាជួយដល់កសិករដែលចិញ្ចឹមមាន់ឱ្យទទួលបាននូវចំណេះដឹងបច្ចេកទេសបន្ថែមសម្រាប់ធ្វើការកែលម្អចំណុចខ្វះខាត និងបញ្ហាប្រឈមនានាធ្វើឱ្យអាជីវកម្មចិញ្ចឹមមាន់ទទួលបានលទ្ធផលល្អ ក្រុមការងារបច្ចេកទេសនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (អេ.អ.ឌី.បី) បានសិក្សាស្រាវជ្រាវរៀបចំឯកសារ **គំរូបច្ចេកទេសចិញ្ចឹមមាន់** ដោយសំយោគចេញពីការសិក្សាស្រាវជ្រាវនូវបទពិសោធន៍នៃការអនុវត្តជាក់ស្តែងរបស់កសិករចិញ្ចឹមមាន់ផ្ទាល់នៅតាមមូលដ្ឋាន និងឯកសារបច្ចេកទេសនានាមួយចំនួនដែលសមស្របទៅនឹងស្ថានភាពបច្ចុប្បន្ន។

ឯកសារស្រាវជ្រាវ **គំរូបច្ចេកទេសចិញ្ចឹមមាន់** នេះ បង្ហាញនូវបង្គុំបច្ចេកទសសំខាន់ៗ ជាពិសេសវិធីការពារនិងព្យាបាលជំងឺ ដោយប្រើពាក្យពេចន៍សាមញ្ញ និងរូបភាពដើម្បីបង្ហាញជូនអ្នកអានក៏ដូចជាប្រជាកសិករដើម្បីងាយយល់ ងាយអនុវត្តន៍។

ក្រុមការងារសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមកសិករចិញ្ចឹមមាន់ដែលផ្តល់ឱកាសឱ្យក្រុមការងារបានជួបសិក្សាដកស្រង់បទពិសោធន៍ពីភាពជោគជ័យ និងបញ្ហាប្រឈមនានាលើអាជីវកម្មចិញ្ចឹមមាន់ ព្រមទាំងបានផ្តល់នូវធាតុចូលសំខាន់ៗជាច្រើនសម្រាប់ការងារចងក្រងឯកសារស្រាវជ្រាវ **គំរូបច្ចេកទេសចិញ្ចឹមមាន់** នេះឡើង។ ទន្ទឹមនឹងនេះដែរ យើងខ្ញុំរង់ចាំទទួលនូវមតិកែលម្អពីសំណាក់ប្រជាកសិករ អ្នកស្រាវជ្រាវកសិកម្ម និងអ្នកជំនាញកសិកម្មទាំងអស់ ដើម្បីឱ្យការរៀបចំឯកសារស្រាវជ្រាវលើកក្រោយៗកាន់តែមានភាពត្រឹមត្រូវថែមទៀតសមស្របទៅតាមស្ថានភាពជាក់ស្តែង ដើម្បីជាប្រយោជន៍ដល់កសិករយកទៅអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព ហើយសង្ឃឹមថា តាមរយៈឯកសារនេះ និងអាស្រ័យដោយការយកចិត្តទុកដាក់អនុវត្តន៍ផ្ទាល់របស់ប្រជាកសិករ នឹងអាចជួយលើកកម្ពស់ផលិតកម្មមាន់នៅកម្ពុជាឱ្យកាន់តែល្អប្រសើរ ដើម្បីផ្គត់ផ្គង់តម្រូវការទីផ្សារក្នុងស្រុក លើកកម្ពស់ជីវភាពគ្រួសារ និងកំណើនសេដ្ឋកិច្ចជាតិ។

សូមអរគុណ !

# មាតិកា

**១/សេចក្តីផ្តើម** ...... ១

**២/បញ្ហាប្រឈម និងដំណោះស្រាយក្នុងការចិញ្ចឹមមាន់ស្រុក** ...... ១

**៣/កត្តាសំខាន់ៗដើម្បីឱ្យការចិញ្ចឹមមាន់ស្រុកទទួលបានជោគជ័យ** ...... ២

៣.១. កត្តាអនាម័យ ...... ២

៣.២. ទឹកស្អាត ...... ២

៣.៣. ចំណី ...... ៣

៣.៣.១. ចំណីកូនមាន់ ...... ៣

៣.៣.២. ចំណីមាន់ជំទង់និងមាន់ធំ ...... ៤

៣.៤. ទ្រុង ...... ៦

៣.៤.១. ទ្រុងមេបាពូជ ...... ៦

៣.៤.២. ទ្រុងកូនមាន់ ...... ៦

៣.៤.៣. សម្រាប់មាន់ជំទង់ និងមាន់ធំ ...... ៨

៣.៥. កត្តាពូជ ...... ៨

៣.៦. កម្មវិធីវ៉ាក់សាំង ...... ៩

៣.៦.១/វ៉ាក់សាំងញូវកាស និងរលាកផ្លូវដង្ហើមលើកទី១ ...... ៩

៣.៦.២/វ៉ាក់សាំងអុតមាន់ ...... ៩

៣.៦.៣/វ៉ាក់សាំងអាសន្នរោគ ...... ១០

៣.៦.៤/វ៉ាក់សាំងញ៉ូវកាស រលាកផ្លូវដង្ហើម និងហ្គូមប្ប៉ូរ ...... ១០

៣.៦.៥/វ៉ាក់សាំងកូរីហ្សា ...... ១១

៣.៧/ការប្រើប្រាស់ថ្នាំការពារជំងឺ និងថ្នាំព្យាបាលជំងឺមាន់ ...... ១១

៣.៨/ជំងឺផ្សេងៗដែលតែងជួបប្រទះលើមាន់ ...... ១២

៣.៨.១/ ជំងឺ ឆ្លងរលាកទងសួត (IB/Infection Bronchitis) ...... ១៣

៣.៨.២/ ជំងឺកុកស៊ីដ្យូស៊ីស (Coccidiosis) ...... ១៤

៣.៨.៣/ ជំងឺញ៉ូវកាស (Newcaslte) ...... ១៤

៣.៨.៤/ ជំងឺមីកូប្លាស្មា (Mycoplama) ...... ១៥

៣.៨.៥/ ជំងឺកូលីបាក់ស៊ីឡូស៊ីស (Colibacillosis) ...... ១៦

**៤/សន្និដ្ឋាន** ...... ១៧

**៥/អនុសាសន៍** ...... ១៧

## ១/សេចក្តីផ្តើម

នៅកម្ពុជាកសិករភាគច្រើននិយមចិញ្ចឹមមាន់ស្រុកនៅតាមផ្ទះបែបយថាផលនិងមានតែកសិករតិចតួចប៉ុណ្ណោះដែលចិញ្ចឹមតាមបែបប្រពលវប្បកម្ម។ កសិករចិញ្ចឹមមាន់គឺសម្រាប់យក សាច់ ស៊ុត និងផ្នែកផ្សេងៗទៀតដូចជា រោម និងស្លាបសម្រាប់ធ្វើអំបោស និងលាមកសម្រាប់ធ្វើជី ដាក់ស្រែ ចំការ។ ដើម្បីឱ្យការចិញ្ចឹមមាន់ទទួលបានទិន្នផលខ្ពស់ កសិករត្រូវដឹងពីបច្ចេកទេសសំខាន់ៗមួយចំនួនក្នុងការថែទាំ ដើម្បីបង្កើនផលិតកម្ម ជាចំណូលជួយដល់សេដ្ឋកិច្ចគ្រួសារ។ បច្ចុប្បន្នដោយសារបម្រែបម្រួលអាកាសធាតុ កសិករចិញ្ចឹមមាន់ចាំបាច់ត្រូវយល់ដឹងពីបច្ចេកទេសថ្មីៗជាច្រើន ដោយពុំអាចចិញ្ចឹមតាមបែបយថាផលដូចមុនបានឡើយ។

## ២/បញ្ហាប្រឈម និងដំណោះស្រាយក្នុងការចិញ្ចឹមមាន់ស្រុក

តាមការចុះសង្កេតផ្ទាល់លើការចិញ្ចឹមមានរបស់កសិករ ទាំងកសិករជោគជ័យ និងកសិករដែលមិនទទួលបានជោគជ័យ ព្រមទាំងបទពិសោធន៍ជាច្រើនឆ្នាំកន្លងមក ក្រុមការងារបច្ចេកទេសនៃធនាគារ អេ.អ.ឌី.ប៊ី បានលើកឡើងនូវបញ្ហាប្រឈមមួយចំនួន និងដំណោះស្រាយដូចខាងក្រោម÷

❖ ***ហេតុអ្វីបានជាកសិករគួរចិញ្ចឹមមាន់ ?***

១-ជាការងារបន្ទាប់បន្សំ អាចប្រកបរបរផ្សេងៗបាន ពិសេសសម្រាប់ស្ត្រី ជៀសវាងការធ្វើចំណាកស្រុក

២- ទទួលបានសាច់ និងស៊ុតជាអាហារប្រចាំថ្ងៃ ជួយទ្រទ្រង់សេដ្ឋកិច្ចគ្រួសារ

៣-លាមកមាន់សម្រាប់ធ្វើជី ដាក់ស្រែ និងដំណាំ ឬបង្កើតជាជីវឧស្ម័ន

❖ ***តើមានកត្តាអ្វីខ្លះដែលធ្វើឱ្យការចិញ្ចឹមមាន់ស្រុក ពុំទទួលបានជោគជ័យ ?***

កត្តាដែលធ្វើឱ្យបងប្អូនកសិករចិញ្ចឹមមាន់ស្រុកពុំទទួលបានជោគជ័យមានមូលហេតុធំៗសំខាន់ដូចជា÷ ការគ្រប់គ្រងជំងឺ ចិញ្ចឹមធំធាត់យឺត អត្រាស្លាប់ខ្ពស់ ការថែទាំនិងប្រព័ន្ធជីវសុវត្ថិភាពមានកម្រិត។

❖ ***តើមានកត្តាអ្វីខ្លះដែលធ្វើឱ្យការចិញ្ចឹមមាន់ស្រុក ទទួលបានជោគជ័យ ?***

១ -កត្តាអនាម័យ (តើយើងគួរធ្វើអនាម័យដោយរបៀបណា)

២ -ទឹកស្អាត (តើគួរផ្តល់ទឹករបៀបណាដែលល្អសម្រាប់សុខភាពមាន់)

៣ -ចំណី (តើគួរផ្តល់ចំណីបែបណាទៅតាមអាយុកាលនៃមាន់)

៤ -ទ្រុង (ទ្រុងរបៀបណាដែលមានផាសុកភាព កក់ក្តៅ ទៅតាមអាយុមាន់)

៥ - កត្តាពូជ (តើគួរជ្រើសរើសមាន់ប្រភេទណាមកធ្វើពូជ ធំធាត់លឿន ងាយស្រួលចិញ្ចឹម និងមានតម្រូវការទីផ្សារខ្ពស់)

៦ - កម្មវិធីវ៉ាក់សាំង និងការប្រើប្រាស់ថ្នាំការពារជំងឺ និងថ្នាំព្យាបាលជំងឺមាន់

៧ - ត្រូវយល់ដឹងពីកត្តាមួយចំនួនដែលតែងជួបប្រទះលើការចិញ្ចឹមមាន់ស្រុក

## ៣/កត្តាសំខាន់ៗដើម្បីឱ្យការចិញ្ចឹមមាន់ស្រុកទទួលបានជោគជ័យ

### ៣.១.**កត្តាអនាម័យ**

ត្រូវបោសសម្អាតទីធ្លា ទ្រុង តើបលាមកមាន់រៀងរាល់ព្រឹក ប្រើប្រាស់ថ្នាំសម្លាប់មេរោគដូចជា TH4, Glutaraldehyde ឬ Formades ដោយបាញ់ក្នុងទ្រុង ជុំវិញទ្រុង និងទីធ្លាឱ្យបានយ៉ាងតិច២ដង/សប្តាហ៍ លាងស្នូកទឹក ស្នូកចំណីយ៉ាងតិចឱ្យបាន១ដង/ថ្ងៃ (អាចសម្អាតដោយប្រើប្រាស់ទឹក និងសាប៊ូដើម្បីសម្លាប់មេរោគដែលបង្កដោយវីរុស និងបាក់តេរី)។

### ៣.២.**ទឹកស្អាត**

ទឹកគឺជាសារធាតុមួយដែលមាន់ពុំអាចខ្វះបាន។ កម្រិតទឹកដែលសមស្របសម្រាប់សត្វមាន់អាចផឹកបាន គឺមានpH ចន្លោះពី ៦.៥ ទៅ ៨.៥។

របៀបថែរក្សាទឹក និងកែប្រែគុណភាពទឹក÷

-ត្រូវថែរក្សាប្រភពទឹកប្រើប្រាស់សម្រាប់ផ្តល់ដល់សត្វមាន់ដោយមិនឱ្យសត្វផ្សេងៗមកផឹកលាយឡំឡើយដូចជាសត្វពាហនៈ បក្សីស្រុក ឬបក្សីព្រៃជាដើម។

-គួរព្យាយាមផ្តល់ទឹកដែលបានលាយថ្នាំសម្លាប់មេរោគដាក់ឱ្យមាន់ផឹក២ថ្ងៃ/សប្តាហ៍ (គួរប្រើនៅថ្ងៃដែលមិនធ្វើវ៉ាក់សាំងឬព្យាបាលមាន់) គួរប្រើ Hydrogenious Peroxide 50% 20ml ក្នុងទឹក១០០លីត្រ(ដើម្បីសម្លាប់មេរោគ) ឬអាចកែប្រែគុណភាពទឹកដោយប្រើប្រាស់វិធីសាស្ត្រចម្រោះបែបធម្មជាតិដូចរូបខាងក្រោមនេះ÷




**តម្រូវការទឹកធៀបនឹងចំណីរបស់សត្វមាន់÷**

-តម្រូវការទឹកស្អាតសម្រាប់មាន់ផឹកគឺទ្វេដងនៃចំណីដែលត្រូវផ្តល់ឱ្យមាន់

-ត្រូវផ្តល់ទឹកឱ្យកូនមាន់តាំងពីពេលញាស់។ កូនមាន់ត្រូវផឹកទឹកសម្រាប់ទៅរំលាយអង្គលឿងក្នុងខ្លួនចាប់ពីញាស់រហូតដល់អាយុបាន២ថ្ងៃ ឬ៤៨ម៉ោងបន្ទាប់ពីពេលញាស់។

-ត្រូវរៀបចំទឹកស្អាតដាក់ក្នុងទ្រុងជាស្រេច មុននឹងដាក់កូនមាន់ចូលទ្រុង

-មិនគួរប្រើទឹកត្រជាក់ឱ្យកូនមាន់ផឹកឡើយ ព្រោះវានាំឱ្យភ្ញាចដល់ប្រព័ន្ធប្រសាទរបស់កូនមាន់ដែលអាចធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធរំលាយអាហារផងដែរ .

-ត្រូវប្រើប្រាស់ថ្នាំ អំព្រូដ្យូម (Amprodium) ឬ អាម៉ុកស៊ីលីន ដើម្បីការពារឱ្យបានសមស្របនៅចន្លោះពេល២៤ម៉ោងក្រោយពេលដាក់កូនមាន់ចូលក្នុងទ្រុង។

*<u>ចំណាំ</u>÷វិធីដែលអាចជួយឱ្យទឹកមានគុណភាពល្អគឺ ប្រើធុងចម្រោះ និងប្រើថ្នាំក្លរ៉ាមីន ៤ទៅ៥ក្រាម/១,០០០លីត្រនៃទឹក ដើម្បីសម្លាប់បាត់តេរី ព្រោះទឹកស្អាតមានសារៈសំខាន់បំផុត។*

## ៣.៣.<u>ចំណី</u>

### ៣.៣.១.ចំណីកូនមាន់

ការផ្តល់ចំណីមិនត្រឹមត្រូវជាកត្តាបរាជ័យក្នុងការចិញ្ចឹមមាន់។ កូនមាន់ចាំបាច់ត្រូវទទួលបានចំណីលឿននិងងាយស្រួល។ នៅពេលដែលកូនមាន់បានស៊ីចំណី វានឹងចផ្តើមរំលាយចំណីជាលើកដំបូង ដូច្នេះត្រូវផ្តល់ចំណីឆ្អិន (ចំណីក្រុមហ៊ុន) ដើម្បីជួយសម្រួលដល់ប្រព័ន្ធរំលាយអាហាររបស់កូនមាន់។ កសិករគួរដាក់ស្នូកចំណីនៅចម្ងាយតិចជាង ១ម៉ែត្រ ពីកូនមាន់។

***ការគ្រប់គ្រង និងប្រើប្រាស់សម្ភារៈ***

-មានថាសដាក់ចំណី និងមានចំណីឱ្យបានគ្រប់គ្រាន់ក្នុងរយៈពេល២៤ម៉ោង/៧ថ្ងៃដំបូង ក្នុងបរិមាណចំណីពី២០ក្រាម ទៅ ៥០ក្រាម/កូនមាន់មួយក្បាល

-គួរពិចារណាក្នុងការប្រើប្រាស់ក្រដាសសម្រាប់ដាក់ទ្រាប់ចំណីពីលើថាស

-ត្រូវប្រើចំណីកូនមាន់ដែលមានគុណភាពល្អ មានក្លិន រសជាតិ មិនជូរ ឬផ្អូម

-មិនត្រូវរៀបចំចំណីទុកមុន១២ម៉ោងមុនពេលកូនមាន់មកដល់

### ៣.៣.២.ចំណីមាន់ជំទង់ និងមាន់ធំ

*ក/ចំណីដែលសម្បូរជាតិប្រូតេអ៊ីន÷ ជួយឱ្យមាន់លូតលាស់លឿន*



















*ខ/ចំណីសម្បូរថាមពល÷ រក្សាសីតុណ្ហភាពក្នុងខ្លួនសត្វ និងចលនាផ្សេងៗ*












| របៀបគណនារកប្រូតេអ៊ីនចំណីមាន់ផ្សំដោយខ្លួនឯង | | | | |
|---|---|---|---|---|
| ល.រ | ឈ្មោះ វត្ថុធាតុដើម | កម្រិតប្រូតេអ៊ីន គិតជាភាគរយ | ចំនួនវត្ថុធាតុដើម គិតជាគីឡូក្រាម | កម្រិត ប្រូតេអ៊ីន |
| ១ | ចុងអង្ករ | 8 | 15 | 1.2 |
| ២ | កន្ទក់ស្រូវលេខមួយ | 11 | 35 | 3.85 |
| ៣ | កន្ទក់ស្រូវសាឡី | 12 | 0 | 0 |
| ៤ | ពោតក្រហម | 9 | 20 | 1.8 |
| ៥ | មើមដំឡូងមី | 3.5 | 0 | 0 |
| ៦ | សណ្តែកសៀង | 38 | 0 | 0 |
| ៧ | កាកសណ្តែកសៀង | 46 | 15 | 6.9 |
| ៨ | កន្ទក់សណ្តែកសៀង | 42 | 0 | 0 |
| ៩ | ម្សៅត្រី | 48 | 10 | 4.8 |
| ១០ | ម្សៅឈាម | 68 | 0 | 0 |
| ១១ | ម្សៅអេចភី | 56 | 5 | 2.8 |
| ១២ | កន្ទក់សណ្តែកបាយ | 26 | 0 | 0 |
| ១៣ | ស្លឹកកន្ធំថេត | 27 | 0 | 0 |
| ១៤ | កាកស្រាបៀ | 25 | 0 | 0 |
| ១៥ | ត្រកួន | 20 | 0 | 0 |
| ១៦ | ក្បាលបង្គា | 36 | 0 | 0 |
| ១៧ | ស្លឹកដំឡូងមី | 34 | 0 | 0 |
| ១៨ | មេចំណីជ្រូកសាច់ | 46 | 0 | 0 |
| សរុប | | | **100** | **21.35** |

វត្ថុធាតុដើមសម្រាប់ផ្សំចំណីអាចផ្លាស់ប្តូរបានតាមអ្វីដែលមានក្នុងស្រុក តម្លៃសមរម្យនិងងាយស្រួលស្វែងរក តែត្រូវគោរពតាមគោលការណ៍អាយុមាន់ និងតម្រូវការប្រូតេអ៊ីនរបស់មាន់÷

-កូនមាន់អាយុ០១ថ្ងៃ ដល់៣០ថ្ងៃ តម្រូវការប្រូតេអ៊ីនយ៉ាងតិច ២១%

-កូនមាន់អាយុ ៣១ថ្ងៃ ដល់ចាប់លក់ តម្រូវការប្រូតេអ៊ីនយ៉ាងតិច ១៨%

-មេបាពូជ តម្រូវការប្រូតេអ៊ីនយ៉ាងតិច ១៦.៥%

-អាចផ្តល់ឱ្យចំណីសម្រេចក្រុមហ៊ុនសុទ្ធ (ប្រភេទចំណីកូនមាន់អាយុក្រោម៣០ថ្ងៃ) ពីព្រោះសម្រាប់កូនមាន់អាយុក្រោម១ខែ ប្រព័ន្ធរំលាយអាហារនៅខ្សោយងាយនឹងមានជំងឺ ដោយសារចំណីផៅចំណែកការផ្សំចំណីខ្លួនឯងនៅមានកម្រិត ដែលពុំអាចពិនិត្យគុណភាពច្បាស់លាស់បាន។

-កូនមាន់ចាប់ពីអាយុ១ខែឡើង អាចប្រើចំណីសម្រេចក្រុមហ៊ុនបន្ត ឬផ្សំចំណីដែលអាចរកបានក្នុងតំបន់ជួយឱ្យថ្លៃដើមផលិតកម្មទាប ប្រាក់ចំណេញកើនឡើង។

## ៣.៤.<u>ទ្រុង</u>

### ៣.៤.១.ទ្រុងមាន់មេបាពូជ

ទ្រុងមានសារៈសំខាន់ណាស់ក្នុងការបង្កាត់ពូជ ផ្តល់ទឹក ចំណី ការគ្រប់គ្រងស៊ុត កន្លែងបង្ខាំងសម្រាប់ធ្វើវ៉ាក់សាំង ត្រួតពិនិត្យសុខភាពមាន់បានគ្រប់ពេល កាត់បន្ថយនូវការចម្លងជំងឺ។ ទ្រុងមេបាមាន់ជាទីតាំងមួយសម្រាប់មាន់រស់នៅផង និងជាកន្លែងការពារមាន់ពីការលួច ការបំផ្លាញពីសត្វចង្រៃ ដូចជាឆ្កែ ឆ្មា និងសត្វផ្សេងៗ។

*ការជ្រើសរើសទីតាំងសាងសង់ទ្រុងមាន់*

ត្រូវមានខ្យល់អាកាសចេញចូលល្អ ទាំងរដូវប្រាំង និងរដូវវស្សា ដីទួលមិនលិច និងជាំទឹក មានដង្ហើមទឹករាក់ (ដីមានសំណើមទឹក) មានម្លប់ជ្រក ប្រភពទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ ឆ្ងាយពីផ្ទះបន្តិច មានពន្លឺព្រះអាទិត្យជះចូលក្នុងទ្រុងនៅពេលព្រឹក និងល្ងាច។




### ៣.៤.២.ទ្រុងកូនមាន់

ត្រូវរៀបចំទ្រុង កម្រាលទ្រុង អំពូលកម្តៅ និងទឹកថ្នាំដាក់ឱ្យកូនមាន់ផឹករយៈពេលពី ១ទៅ២ថ្ងៃ

*កម្រាលទ្រុង ៖*

- គេអាចប្រើដូចជា អង្កាម កម្ទេចឈើ (កម្ទេចរណារ) ឬដីខ្សាច់(កម្ពស់អតិបរមា ៥សង់ទីម៉ែត្រ)
- មានលទ្ធភាពស្រូបយកជាតិទឹក
- មានលទ្ធភាពសំយោគលាមកមាន់
- ត្រូវតែស្អាត គ្មានបាក់តេរី និងពពួកផ្សិត

## ឆ/ សីតុណ្ហភាពក្នុងទ្រុងសម្រាប់កូនមាន់

| ការដាក់កម្តៅក្នុងទ្រុងសម្រាប់កូនមាន់ទើបញាស់ | ដាក់កូនមាន់ឱ្យត្រូវពន្លឺព្រះអាទិត្យនៅពេលព្រឹក |
|---|---|
|  |  |

-កូនមាន់មិនអាចគ្រប់គ្រងសីតុណ្ហភាពរាងកាយក្នុងខ្លួនរហូតដល់អាយុ៥ថ្ងៃ ដូច្នេះសូមកុំសន្សំសំចៃលើការផ្តល់កម្តៅនៅថ្ងៃដំបូង (កូនមាន់អាចបង្ហាញនូវលក្ខណៈតាមរយៈរូបភាពខាងក្រោម)÷




-ជើងរបស់កូនមាន់ត្រូវមានកម្តៅ (ត្រួតពិនិត្យដោយយកជើងមាន់ដាក់លើបបូរមាត់របស់អ្នក)

-សីតុណ្ហភាពក្នុងរាងកាយកូនមាន់ថ្ងៃទី០១ គឺមិនទាបជាង ៣៨អង្សាសេ និងមិនខ្ពស់ជាង៤១អង្សាសេ (ចំណុចល្អគឺនៅចន្លោះពី ៣៩ ទៅ៤០អង្សាសេ)

### ៣.៤.៣.សម្រាប់មាន់ជំទង់ និងមាន់ធំ

ត្រូវមានកម្រាលបាតទ្រុងដូចជាអង្កាមឬកម្ទេចរណារសម្រាប់រដូវវស្សា និងនៅរដូវប្រាំងប្រើកម្រាលដីខ្សាច់ ថែមទាំងមានទ្រនើរសម្រាប់មាន់ដេកពេលយប់(ករណីចិញ្ចឹមមាន់មិនព្រលែងចេញក្រៅទ្រុង)។ ផ្ទៃក្រឡាទ្រុងមាន់ ១ម៉ែត្រការ៉េ អាចដាក់មាន់បាន÷

- មាន់អាយុ ២ទៅ ៣ខែ អាចដាក់បានពី ១៥ទៅ ២០ក្បាល
- មាន់អាយុ ៣ទៅ ៤ខែ អាចដាក់បានពី ៨ទៅ ១០ក្បាល
- មាន់អាយុ ៤ទៅ ៥ខែ អាចដាក់បានពី ៤ទៅ ៥ក្បាល




### ៣.៥.<u>កត្តាពូជ</u>

ត្រូវទិញមាន់មកចិញ្ចឹមដោយដឹងពីប្រវត្តិ និងប្រភពច្បាស់លាស់ពីកសិដ្ឋានដែលពុំមានផ្ទុះជំងឺ មិនមានការជាន់ឈាមគ្នា។ កូនមាន់ត្រូវមានរូបរាងមាំមួន រហ័សរហួន កែវភ្នែកភ្លឺថ្លា រោមភ្លឺរលោង មានប្រវត្តិទទួលកម្មវិធីធ្វើវ៉ាក់សាំងគ្រប់គ្រាន់ត្រឹមត្រូវ។



**ការជ្រើសរើសមាន់បា**

-មាឌធំសង្ហា ពេញវ័យ អាយុចាប់ពី ៧ទៅ ៨ខែ

-សុខភាពល្អ ទម្ងន់ចាប់ពី ២,៥ទៅ ៣,២គីឡូក្រាម/ក្បាល

-ចរិតស្លូតបូត ពូកែជាន់មេ

-ប្រវត្តិមេបាល្អ មិនជាន់ឈាម មិនមានជំងឺតំណពូជ

**ការជ្រើសរើសមាន់មេ**

-មានមាឌធំល្មម ដងខ្លួនវែង ទម្ងន់ចាប់ពី ១.៧ ទៅ ២.៥គីឡូក្រាម/ក្បាល

-ជើងពណ៌លឿង កន្ទុយច្រើន និងរោមក្រាស់ទន់រលោង

-សុខភាពល្អ ប្រវត្តិមេបាល្អ មិនជាន់ឈាម

-ចរិតស្លូតបូត ពូជមាន់ផ្តល់ស៊ុតច្រើន សាយកូន និងពូកែថែទាំកូន

## ៣.៦.កម្មវិធីវ៉ាក់សាំង

### ៣.៦.១.វ៉ាក់សាំងញូវកាស និងរលាកផ្លូវដង្ហើម

បន្តក់វ៉ាក់សាំងលើកទី១នៅពេលកូនមាន់អាយុពី០១ថ្ងៃទៅ០៧ថ្ងៃ ប្រសិទ្ធភាពបាន៣សប្តាហ៍និង រំលឹកនៅពេល៣សប្តាហ៍ក្រោយ (ជាលើកទី២)




**អាចបន្តក់តាមភ្នែក ឬមាត់**

### ៣.៦.២.វ៉ាក់សាំងជំងឺអុតមាន់៖

ធ្វើនៅពេលកូនមាន់អាយុពី ១០ថ្ងៃ ទៅ១៥ថ្ងៃ ដោយការជួសស្លាបរងតែម្តងគត់ (នៅចំតំបន់ត្រីកោណ)



### ៣.៦.៣/វ៉ាក់សាំងជំងឺអាសន្នរោគ ៖

ប្រើប្រាស់លើកូនមាន់ចាប់ពីអាយុ៤៥ថ្ងៃ ដោយចាក់លើសាច់ដុំទ្រូង ០,៥សេសេ/ក្បាល និងរំលឹកនៅពេលមាន់មានអាយុ៦៥ ថ្ងៃម្តងទៀត បន្ទាប់មកចាក់រៀងរាល់៣ខែម្តងសម្រាប់មាន់ទុកធ្វើពូជ។




ជាប្រភេទវ៉ាក់សាំងងាប់ អាចបូមប្រើប្រាស់តាមចំនួនមាន់ និងវ៉ាក់សាំងសល់ក្នុងដបទុកប្រើថ្ងៃក្រោយ




***ជាប្រភេទវ៉ាក់សាំងងាប់***

-រក្សានៅសីតុណ្ហភាពចន្លោះពី២ ទៅ ៨អង្សាសេ

-បូមយកទៅប្រើប្រាស់តាមចំនួនមាន់

-បន្ទាប់ពីបូមយកទៅប្រើប្រាស់ហើយវ៉ាក់សាំងនៅសល់ត្រូវរក្សាទុកក្នុងទូទឹកកកវិញភ្លាម

-ម្ជុលនិងស៊ីរ៉ាំងសម្រាប់បូមត្រូវមានអនាម័យត្រឹមត្រូវ។

### ៣.៦.៤/វ៉ាក់សាំងញូវកាស រលាកផ្លូវដង្ហើម និងហ្គុមបូរ៉ូ ៖




ជាវ៉ាក់សាំងដែលគេបានបង្កើតឡើងដោយបូកបញ្ចូល៣មុខក្នុងដបតែមួយងាយស្រួលប្រើប្រាស់ និងចំណេញពេលវេលា។

-ជាប្រភេទវ៉ាក់សាំងងាប់

-រក្សានៅសីតុណ្ហភាពចន្លោះពី២ ទៅ ៨អង្សាសេ

-បូមយកទៅប្រើប្រាស់តាមចំនួនមាន់

-បន្ទាប់ពីបូមយកទៅប្រើប្រាស់ហើយវ៉ាក់សាំងនៅសល់ត្រូវរក្សាទុកក្នុងទូទឹកកកវិញភ្លាម

-ម្ជុលនិងស៊ីរ៉ាំងសម្រាប់បូមត្រូវមានអនាម័យត្រឹមត្រូវ។

## ៣.៦.៥/វ៉ាក់សាំងគូរីហ្សា៖




ចាក់កូនមាន់អាយុ៣៥ថ្ងៃឡើងចាក់សាច់ដុំទ្រូងមួយក្បាល០,៥សេសេ រយៈពេលរំលឹករៀងរាល់៣ខែម្តង។

-ជាប្រភេទវ៉ាក់សាំងងាប់

-រក្សានៅសីតុណ្ហភាពចន្លោះ២ទៅ៨អង្សាសេ

-បូមយកទៅប្រើប្រាស់តាមចំនួនមាន់

-បន្ទាប់ពីបូមយកទៅប្រើប្រាស់ហើយវ៉ាក់សាំងនៅសល់ត្រូវរក្សាទុកក្នុងទូទឹកកកវិញភ្លាម

-ម្ជុលនិងស៊ីរ៉ាំងសម្រាប់បូមត្រូវមានអនាម័យត្រឹមត្រូវ។

## ៣.៧/ការប្រើប្រាស់ថ្នាំការពារជំងឺ និងថ្នាំព្យាបាលជំងឺមាន់




ថ្នាំទាំង៣មុខក្នុងរូបភាពខាងលើនេះ សមប្រកបនឹងជំងឺហើមមុខ ហើមក្បាល ផ្តាសាយ ហៀរសំបោរ មិនរលាយចំណីក្នុងគែ

***របៀបប្រើ៖*** សម្រាប់ការពារជំងឺ៖បើកញ្ចប់ ត្រូវជាមួយទឹក ១០-១៥លីត្រ ប្រើជាប់៣ថ្ងៃ មួយថ្ងៃផឹកម្តង ផ្អាក៥ថ្ងៃទៅ៧ថ្ងៃ រួចបន្តផឹកជាប់៣ថ្ងៃបន្តទៀត

***ការព្យាបាល៖*** ៣កញ្ចប់លាយទឹក៦ទៅ៨លីត្រផឹកមួយថ្ងៃ២ដង ព្រឹកល្ងាច ប្រើជាប់៥ថ្ងៃទៅ៧ថ្ងៃ។










ថ្នាំទាំង៣មុខក្នុងរូបភាពខាងលើនេះ សមប្រកបនឹងជំងឺរាគស រាគខៀវ លាមកស្អិតជាប់គូទ អត់រំលាយអាហារក្នុងគៃ និងការពារជំងឺផ្លូវដង្ហើម។

***សម្រាប់ការពារជំងឺ÷*** បីកញ្ចប់ ត្រូវជាមួយទឹក ១០-១៥លីត្រ ប្រើ៣ថ្ងៃ មួយថ្ងៃផឹកម្តង ផ្អាក៥ថ្ងៃទៅ៧ថ្ងៃ រួចបន្តផឹក៣ថ្ងៃទៀត

***ការព្យាបាល÷*** ៣កញ្ចប់លាយទឹក៦ទៅ៨លីត្រផឹកមួយថ្ងៃ២ដង ព្រឹកល្ងាច ប្រើជាប់៥ថ្ងៃទៅ៧ថ្ងៃ។







ថ្នាំទាំង២មុខក្នុងរូបភាពខាងលើនេះ សមប្រកបនឹងជំងឺ រាគឈាម ឬជំងឺកុកស៊ីដ្យូស៊ីស។

ការព្យាបាល÷ ២កញ្ចប់លាយទឹក៥ទៅ៦លីត្រផឹកមួយថ្ងៃ២ដង ព្រឹកល្ងាច ប្រើជាប់៣ថ្ងៃ ខាន២ថ្ងៃ ដាក់ផឹក៣ថ្ងៃទៀត។

## ៣.៨/ជំងឺផ្សេងៗដែលតែងជួបប្រទះលើមាន់ ÷

ជំងឺលើសត្វមាន់មានច្រើនមុខណាស់ ប៉ុន្តែជំងឺដែលតែងសង្កេតឃើញញឹកញាប់កើតលើមាន់ស្រុក មានដូចតទៅនេះ÷

### ៣.៨.១/ជំងឺផ្លូវរលាកទងសួត (IB/Infection Bronchitis)



ជាប្រភេទជំងឺមួយដែលបង្កឡើងដោយវីរុស ឆ្លងលើមាន់គ្រប់អាយុ ការចម្លងលឿនពីហ្វូងមួយទៅហ្វូងមួយ ប៉ុន្តែអត្រាស្លាប់មានកម្រិតទាប។

- *<u>រោគសញ្ញាខាងក្រៅ</u>*







-អាការៈផ្លូវដង្ហើម (Massachussets Strains មានកណ្តាស់

-ខូចក្រលៀន(Variant Strains) មានរាគ(ទឹក)

-បញ្ហាប្រព័ន្ធភាពសាំចុះខ្សោយ មានភាគរយបាត់បង់ខ្ពស់

- *<u>ការវះកាត់</u>*

-ក្រលៀនមានសភាពជ្រាយហាក់បីដូចជាខ្វរ

-តម្រង់នោមឡើងប៉ោងនិងមានឈាម

- *<u>ការព្យាបាល÷</u>*

-Amoxicillin+Enrofloxacin ឬ Amoxicilin +Colistin

(ប្រើចំនួន០៣ថ្ងៃជាប់ៗគ្នា)

-បន្ទាប់មកប្រើ វីតាមីន/មីណេរ៉ាល/ អេឡិចត្រូលីត្រ ចំនួន៣ថ្ងៃបន្ទាប់។

**៣.៨.២/ជំងឺកុកស៊ីដ្យូស៊ីស** (Coccidiosis)

ជាប្រភេទជំងឺបង្កឡើងដោយពពួកប្រូតូស្វ័អ៊ែរ ឆ្លងរាលដាលទូទាំងប្រទេស តាមរយៈទឹក ចំណីកខ្វក់ និងការផ្លាស់ប្តូរអាកាសធាតុញឹកញាប់។




- *រោគសញ្ញាខាងក្រៅ* អាការៈដំបូង÷

-ភាគរយងាប់ គ្មាន

-លាមកសើម

-ស្រកទម្ងន់លឿន

-FCR និងកំណើនលូតលាស់ទាប

-ការស៊ីចំណីថយចុះ

-មានស្លេសពណ៌ក្រហមនៅលើលាមក (ស្លូត)

- *ការវះកាត់*

-ខ្នែងពោះវៀនមានឈាម

-ស្នាមអុជពណ៌សលើទងពោះវៀន

-មាន់ដែលងាប់មានសាច់ទ្រូងស្លេក

- *ការព្យាបាល*

-ប្រើ Trimethoprim/Sulfonamides+ Amoxicillin

-Amprolium

-ប្រសិនបើជួបបញ្ហានៅវគ្គមុន គួរឱ្យ Toltrazuril ចន្លោះថ្ងៃទី១៣ ទៅ១៥ នៅវគ្គបន្ទាប់

-ប្រសិនបើមិនជួបបញ្ហាជំងឺកុកស៊ីដ្យូស៊ីសនៅវគ្គមុន គួរប្រើ CUSO4 ចន្លោះថ្ងៃទី១៣ដល់១៥ (ជួយដល់ការរំលាយអាហារ)

ក្នុងករណីមានប្រតិកម្មក្រោយធ្វើវ៉ាក់សាំងគួរប្រើថ្នាំប្រឆាំងនឹងការរលាកដូចជា: Paracetamol

**៣.៨.៣/ជំងឺញូវកាស** (Newcaslte)

ជាប្រភេទជំងឺដែលបង្កឡើងដោយវីរុស មិនមានថ្នាំព្យាបាលទេ ឆ្លងរាលដាលរហ័ស តាមរយៈខ្យល់ ការប៉ះពាល់ផ្ទាល់ និងសម្ភារៈប្រើប្រាស់ក្នុងកសិដ្ឋានរួមជាមួយសត្វដែលមានជំងឺ ។ល។



- *រោគសញ្ញាខាងក្រៅ*

អាការៈដំបូង÷

-អាការៈផ្លូវដង្ហើម មានកណ្ដាស់

-អាការៈក្នុងពោះវៀន ឃើញមានរាគ(ពណ៌ខៀវ)

-រមួលក ឬក្បាល

-ការស៊ីចំណីធ្លាក់ចុះ

-មុខ និងជើងស្វិត

- *ការវះកាត់*

-មានឈាម ឬស្នាមអុចលើទងកោះ

-ស្នាមអុចឈាមនៅលើបំពង់ខ្យល់ និងភ្នាសសើមភ្នែក

- *ការការពារ*

-ត្រូវប្រើប្រាស់វ៉ាក់សាំងទៅតាមកម្មវិធីណែនាំឱ្យបានត្រឹមត្រូវ

-ក្នុងករណីមានប្រតិកម្មក្រោយធ្វើវ៉ាក់សាំងគួរប្រើថ្នាំប្រឆាំងនឹងការរលាកដូចជាៈ Paracetamol

**៣.៨.៤/ជំងឺមីកូប្លាស្មា** (Mycoplama)

ជាប្រភេទជំងឺបង្កឡើងដោយពពួកបាក់តេរី ច្រើនកើតឡើងនៅកន្លែងដែលមានបរិស្ថានមិនស្អាត ខ្យល់អាកាសចេញចូលមិនល្អ



- *រោគសញ្ញាខាងក្រៅ*

អាការៈដំបូង÷

-ហើមប៉ោងមុខ និងត្របកភ្នែក

-ហៀរទឹកសំបោរថ្លាៗចេញតាមច្រមុះ

-ហៀរទឹកភ្នែកជាប្រចាំ

-ពិបាកដកដង្ហើម

-ហើមបាតជើង សន្លាក់ជើង និងពិការ

-ការស៊ីចំណីថយចុះ

- *ការវះកាត់*

-រលាកទងសួត និងកូនថង់សួត

-រលាកជុំវិញថ្លើម

-ហើមសួត

- *ការព្យាបាល*

-ប្រើទីឡូស៊ីន(Tylosin) ឬតេត្រាស៊ីគ្លីន(Tetracycline) និងប្រើថ្នាំសម្រាប់ប៉ូវកម្លាំងអាដេអឺ បេកំផ្លេច

-ករណីកម្តៅក្នុងខ្លួនមាន់ឡើងខ្លាំង គួរប្រើប្រាស់ថ្នាំបញ្ចុះកម្តៅជាមុនសិន

**៣.៨.៥/ជំងឺកូលីបាក់ស៊ីឡូស៊ីស** (Colibacillosis)

ជាប្រភេទជំងឺបង្កឡើងដោយពពួកបាក់តេរី ច្រើនកើតឡើងនៅពេលសត្វស្រ្តេស ជាប្រភេទជំងឺឱកាសនិយមបន្ទាប់ពីមាន់មានជំងឺ មីកូប្លាស្មា រលាកទងសួត និងច្រើនបង្កជំងឺតាមរយៈចំណី ទឹក គ្មានគុណភាព គ្មានអនាម័យ










- *<u>រោគសញ្ញាខាងក្រៅ</u>*

អាការៈដំបូង÷

-រាគដោយសាររលាកពោះវៀន

-សំកុក បិទភ្នែកសំងំដេក

-រោមបះ ប្រឹងដកដង្ហើម ក្អក និងដកដង្ហើមញ្ជូរសំលេង

-ការស៊ីចំណីថយចុះ

-អត្រាស្លាប់ខ្ពស់ចំពោះកូនមាន់

- *<u>ការវះកាត់</u>*

-មានខ្ទុះខាប់នៅក្នុងថង់ខ្យល់ ស្រោមបេះដូង និងនៅលើផ្ទៃនៃបេះដូង រលាកថ្លើម និងសួត

- *<u>ការព្យាបាល</u>*

-ប្រើ Enrofloxacine ឬ Tetracycline រយៈពេល៣ទៅ៥ថ្ងៃ

ក្នុងករណីមានប្រតិកម្មក្រោយធ្វើវ៉ាក់សាំងគួរប្រើថ្នាំប្រឆាំងនឹងការរលាកដូចជា÷ Paracetamol

-*<u>ចំពោះការព្យាបាល</u>* ពុំមានប្រសិទ្ធភាពនោះទេ បើសិនជាម្ចាស់ កសិដ្ឋានមិនបានផ្តល់នូវ ទឹកស្អាត ចំណីស្អាត រួមទាំងបរិស្ថានរស់នៅស្អាត និងផ្តោតទៅលើការធ្វើអនាម័យជាពិសេស។

## ៤/សន្និដ្ឋាន

ការចិញ្ចឹមមាន់ស្រុក គឺជារបរសំខាន់មួយបន្ទាប់ពីការធ្វើស្រែចម្ការរបស់ប្រជាកសិករ ដើម្បីបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារ និងជាម្ហូបអាហារប្រចាំថ្ងៃ។ ការចិញ្ចឹមមាន់ស្រុកតាមផ្ទះ តែងតែជួបប្រទះបញ្ហាជំងឺផ្សេងៗជាច្រើនដូចជា ការលូតលាស់យឺត ចិញ្ចឹមមិនគង់ទទួលការរាតត្បាតខ្លាំងពីជំងឺឆ្លងដែលជាមូលហេតុបណ្តាលឱ្យអ្នកស្រុកចិញ្ចឹមមាន់បរាជ័យ ពុំមានមាន់សម្រាប់លក់ទៀងទាត់ និងបរិភោគបានគ្រប់គ្រាន់ កសិករដែលមិនសូវស្វែងយល់ពីបច្ចេកទេសចិញ្ចឹមមាន់ធន់នឹងការប្រែប្រួលអាកាសធាតុជាដើមហេតុបណ្តាលឱ្យមាន់ផ្ទុះជម្ងឺងាប់២ ទៅ៣ដងក្នុងមួយឆ្នាំ ការចិញ្ចឹមមាន់ពុំទទួលបានទិន្នផលខ្ពស់ខាតពេលវេលា និងថវិកា។

ដូច្នេះក្រោយពីមើលឃើញភាពបរាជ័យខាងលើ ទើបក្រុមការងារបច្ចេកទេសនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្មបានរៀបចំឯកសារគំរូស្រាវជ្រាវបច្ចេកទេសការចិញ្ចឹមមាន់ស្រុកនេះឡើង ដើម្បីជួយដល់បងប្អូនប្រជាកសិករចិញ្ចឹមមាន់ស្រុកឱ្យទទួលបាននូវផលិតភាពខ្ពស់ ដំណោះស្រាយបច្ចេកទេសសមស្របដោយប្រើប្រាស់ឱ្យមានប្រសិទ្ធភាពនូវធនធានដែលមានស្រាប់តាមមូលដ្ឋាន កាត់បន្ថយការចំណាយដែលមិនចាំបាច់ យល់ពីរបៀបបង្កាត់ពូជ ថែទាំមាន់ ការការពារ និងព្យាបាល ដើម្បីទទួលបានជោគជ័យក្នុងរបរចិញ្ចឹមមាន់ស្រុក។

## ៥/អនុសាសន៍

ការចិញ្ចឹមមាន់ស្រុក កសិករគួរព្យាយាមស្វែងរកវត្ថុធាតុដើមចំណីមានស្រាប់ក្នុងភូមិដូចជា÷

-ការទិញពោត ស្រូវ សណ្តែក នៅរដូវកាលប្រមូលផលស្តុកទុកសម្រាប់ចំណីមាន់

-បន្ថែមការដាំដំណាំចំណីមាន់ដូចជា÷ ត្រកួន កន្ទំថេត ដើមឆៃយ៉ា (បន្លែផ្អែម) ចកអាសូឡា ពូជស្មៅសម្រាប់ជាចំណីមាន់ ដើមថ្មី រុក្ខជាតិផ្សេងៗទៀតដែលមាន់អាចស៊ីបាន

-ការចិញ្ចឹមជន្លេនក្រហម និងការចិញ្ចឹមដង្កូវជាចំណីមាន់

-ធ្វើវ៉ាក់សាំងផ្តាសាយបក្សី សម្រាប់តែតំបន់ដែលមានផ្ទុះជំងឺ (ករណីដែលអាជ្ញាធរមានសមត្ថកិច្ចបានអនុញ្ញាតឱ្យតំបន់នោះប្រើប្រាស់)

-ថែទាំមាន់ឱ្យមានសុខភាពល្អ រៀបចំប្រព័ន្ធជីវសុវត្ថិភាព និងធ្វើអនាម័យទ្រុងជាប្រចាំថ្ងៃ

-ការដាក់ទឹកចំណីឱ្យបានទៀងទាត់ពេលវេលា ជៀសវាងមាន់មានបញ្ហាស្ត្រេស

**ឯកសារពិគ្រោះស្រាវជ្រាវ÷**


១-ឯកសារបច្ចេកទេសចិញ្ចឹមមាន់ស្រុករបស់ដេប៉ូលក់ថ្នាំសត្វចល័ត និងទិញលក់មាន់ស្រុក

២- ស្តង់ដានៃការធ្វើរោគវិនិច្ឆ័យជំងឺសត្វរបស់សាស្ត្រាបណ្ឌិត មាស សុទ្ធី ឆ្នាំ ២០១៣

៣- ក្រុមហ៊ុនថ្នាំកសិកម្មមួយចំនួននៅកម្ពុជា

៤- គម្រោងចិញ្ចឹមសត្វកម្ពុជា សហគមន៍អឺរ៉ុប

៥-Colibacillosis in Chickens (poultrydvm.com)

៦-Newcastle disease in Chickens (poultrydvm.com)

៧-Infectious Bronchitis in Chickens (psu.edu)

៨-Coccidiosis in Chickens: Symptoms, Treatment, and Prevention (morningchores.com)

៩-Mycoplasma in Chickens: Most Important Points for Poultry Farmer (thevetexpert.com)